# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

## (អេឃ្វាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

# វគ្គតំរង់ទិសស្តីអំពីវិធានការចម្រុះគ្រប់គ្រងដំណាំ

## សម្រាប់

## សមាជិកក្រុមចំបង,នាយក,អ្នកសម្របសម្រួលអោយ ភី អ៊ឹមខេត្ត និង តំណាងសហគមន៍




អង្គការអប់រំពិភពលោក

ភ្នំពេញ

ខែ វិច្ឆិកា ឆ្នាំ ២០០៦

# សិក្ខាសាលាស្តីអំពីវិធានការចម្រុះគ្រប់គ្រងធំណាំ

| លរ. | មាតិកា | រយៈពេល | ទំព័រ |
|---|---|---|---|
| 1 | **ការផ្តើមសិក្ខាសាលា** | | |
| 1.1 | ការណែនាំឱ្យស្គាល់គ្នា/កំណត់បទបញ្ជា ពេលវេលាសម្រាប់សិក្ខាសាលា | **08 : 00 – 08 : 15**<br>១៥ នាទី | |
| 1.2 | គោលបំណងសិក្ខាសាលា/ ផលរំពឹងទុក | | |
| 2 | **ការពិពណ៌នាពីកម្មវិធី អាយភីអ៊ឹម** | | |
| 2.1 | អាយ ភី អ៊ឹម ជាអ្វី? | **08 : 15 – 08 : 45**<br>៣០ នាទី | |
| 2.2 | គោលបំណងបញ្ចូលកម្មវិធី **អាយភីអ៊ឹម** ទៅក្នុងកម្មវិធីសិក្សារបស់សាលា | **08 : 45 - 09 : 15**<br>៣០ នាទី | |
| | សម្រាក | ១៥ នាទី | |
| 3 | **ការរៀបចំដំណើរការសាលារៀនស្រែសិស្សមួយកន្លែង** | | |
| 3.1 | ការបង្កើត គណៈកម្មការគ្រប់គ្រងកម្មវិធី ឬ ក្រុមគាំទ្រ អាយភីអ៊ឹម ប្រចាំសាលា | **09 : 30 – 10 : 00**<br>៣០ នាទី | |
| 3.2 | **ការត្រៀមរៀបចំសម្រាប់សាលារៀនស្រែ អាយ ភី អ៊ឹម**<br>ក. ការកំណត់ទីតាំងស្រែបង្ហាញ និង កន្លែងសិស្សរៀន<br>ខ. ការកំណត់អ្នកបង្រៀន អាយភីអ៊ឹម ប្រចាំសាលា | **10 : 00 – 11 : 30**<br>១ម៉ោង ៣០ នាទី | |
| | សម្រាកអាហារថ្ងៃត្រង់ | | |
| | គ. ការជ្រើសរើសសិស្ស<br>ឃ. ជួបប្រជុំជាមួយអាណាព្យាបាល | **02 : 00 – 02 : 30**<br>៣០ នាទី | |
| 3.3 | **ការកំណត់ថវិកា** | **02 : 30 – 03 : 00**<br>៣០ នាទី | |
| | សម្រាក | ១៥ នាទី | |
| 3.4 | **ការធ្វើផែនការអនុវត្តជាក់ស្តែង :** | **03 : 15 – 04 : 00**<br>៤៥ នាទី | |

<u>សំគាល់:</u>

ព្រឹកៈ ៨:00 -11:30 ល្ងាចៈ 2:00 – 4:00

រយៈពេល១ថ្ងៃ សម្រាកៈ ព្រឹក ១៥ នាទី ល្ងាច ១៥ នាទី

# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## ឯកសារ សម្រាប់អ្នកសម្របសម្រួល
## វគ្គតម្រង់ទិសស្តីពីវិធានការចម្រុះគ្រប់គ្រងដំណាំ

**សម្រាប់**

**សមាជិកក្រុមចម្បង នាយក អ្នកសម្របសម្រួល អាយតីអ៊ឹម និង តំណាងសហគមន៍**

**វិច្ឆិការ ២០០៦**

# ការតម្រង់ទិសស្ដីអំពីវិធានការចម្រុះគ្រប់គ្រងដំណាំដល់សមាជិកក្រុមចម្បងទទួលបន្ទុក IPM និង នាយកសាលា

| វគ្គទី១: សេចក្ដីផ្ដើមសិក្ខាសាលា,គោលបំណង និង លទ្ធផលដែលរំពឹងទុក | |
|---|---|
| **ខ្លឹមសារនិងសេចក្ដីសង្ខេប:** | **១.១ ការផ្ដើមសិក្ខាសាលា:** នេះជាការចាប់ផ្ដើម ដោយអ្នកសម្របសម្រួល និង សិក្ខាកាមណែនាំខ្លួន ម្ដងម្នាក់ៗដើម្បីឱ្យស្គាល់គ្នាទៅវិញទៅមក ។ ធ្វើការពិនិត្យមើលកម្មវិធីសិក្ខាសាលាទាំងមូល និងបង្កើតនូវ បទបញ្ជាមួយសម្រាប់អនុវត្តក្នុងសិក្ខាសាលា ។ |
| **រយៈពេល:** | ១០នាទី |
| **សម្ភារដែលត្រូវការ:** | ▪ ឯកសារចែកស្ដីអំពីកម្មវិធីសិក្ខាសាលា |

| វត្ថុបំណង | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
|---|---|---|
| | **ការចាត់ចែងអង្គុយតាមក្រុម** | |
| ▪ សិក្ខាកាមត្រូវបានរៀបចំតាមលក្ខណៈដែលមានភាពងាយស្រួលក្នុងការសម្របសម្រួល និង ពិភាក្សាគ្នា ។ | មុនពេលចាប់ផ្ដើមសិក្ខាសាលាអ្នកសម្របសម្រួលគួររៀបចំកន្លែងសិក្ខាសាលាឱ្យមានលក្ខណៈដែលអាចឱ្យសិក្ខាកាមចូលរួមយ៉ាងសកម្ម និងត្រូវប្រាកដថាសិក្ខាកាមអាចធ្វើចលនាបានដោយងាយស្រួល ។ អ្នកសម្របសម្រួលអាចស្នើឱ្យសិក្ខាកាម អង្គុយជារាងអក្សរ U ឬ រង្វង់ ដោយប្រើតុ កៅអី ឬ អង្គុយលើកន្ទេល អាស្រ័យទៅតាមទីកន្លែង ។ | ▪ សិក្ខាកាមជួយរៀបចំទីកន្លែងសិក្ខាសាលា ។ |
| | **ការណែនាំឱ្យស្គាល់គ្នា** | |
| ▪ សិក្ខាកាមបានស្គាល់គ្នាកាន់តែច្បាស់ងាយស្រួលក្នុងការរៀនសូត្រពីគ្នា ។ | ▪ អ្នកសម្របសម្រួលចាប់ផ្ដើមសិក្ខាសាលា ដោយការស្វាគមន៍ ដ៏កក់ក្ដៅដល់សិក្ខាកាមទាំងអស់ហើយបន្តដោយការណែនាំខ្លួនអ្នកសម្របសម្រួល និង សិក្ខាកាម ម្នាក់ម្ដងៗ ។ ក្នុងករណីដែលសិក្ខាកាម ធ្លាប់បានស្គាល់គ្នារួចមកហើយការណែនាំម្នាក់ម្ដងមិនជាការចាំបាច់ទេ ។ | ▪ សិក្ខាកាមណែនាំខ្លួនរបស់គេដោយប្រាប់ឈ្មោះ តួនាទី ទីលំនៅ និង ពត៌មានផ្សេងទៀតដែលទាក់ទង ។ |
| | **បទបញ្ជាផ្ទៃក្នុង** | |
| ▪ សិក្ខាកាមឯកភាពលើបទបញ្ជា និង កម្មវិធីរបស់សិក្ខាសាលា ។ | ▪ អ្នកសម្របសម្រួលរំលឹកពីបទបញ្ជាមួយចំនួនសម្រាប់ដំណើរការអង្គសិក្ខាសាលា ដោយធ្វើការពិភាក្សាលើចំណុចមួយចំនួនដូចជា :<br>- តើសិក្ខាសាលាគួរចាប់ផ្ដើមនិងបញ្ចប់នៅម៉ោងប៉ុន្មាន?<br>- តើសិក្ខាសាលាគួរសម្រាកម៉ោងប៉ុន្មាន?<br>- និយាយម្នាក់ម្ដងៗ និង ស្ដាប់គ្នាទៅវិញទៅមក | ▪ ពិភាក្សារកការឯកភាពគ្នាបង្កើតនូវបទបញ្ជាមួយសម្រាប់ អនុវត្តក្នុងសិក្ខាសាលា ។ |

| | | |
|---|---|---|
| ▪ សិក្ខាកាមដឹងពីកម្មវិធីរបស់សិក្ខាសាលាដែលអាចជួយគេរៀបចំខ្លួនសម្រាប់ការចូលរួម ។ | - គោរពពេលវេលាដែលបានកំណត់ ។<br>- ការបញ្ជាក់ពីថវិកាដែលត្រូវឧបត្ថម្ភ ។<br>▪ អ្នកសម្របសម្រួលដឹកនាំការពិភាក្សាដោយសរសេរលទ្ធផលដែលបានព្រមព្រៀងត្រូវសសេរលើក្រដាសធំ ហើយបិទបង្ហាញដើម្បីអនុវត្ត ក្នុងរយៈពេលនៃ អង្គសិក្ខាសាលា ។<br><br>**ការបង្ហាញពីកម្មវិធីសិក្ខាសាលា**<br>▪ ចែកកម្មវិធីសិក្ខាសាលាហើយទុកពេលអោយសិក្ខាកាមអាន និងលើកជាសំណួរ ។<br>▪ អ្នកសម្របសម្រួលគួរតែធ្វើការកែតម្រូវកម្មវិធីសិក្ខាសាលាប្រសិនបើមានការចាំបាច់ ហើយធ្វើការបញ្ជាក់ឡើងវិញជាមួយសិក្ខាកាម ។ | ▪ សិក្ខាកាមឯកភាពលើកម្មវិធី របស់សិក្ខាសាលា ។ |



| | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្ដីសង្ខេប:** | **១. គោលបំណងសិក្ខាសាលា:** នៅក្នុងផ្នែកនេះសិក្ខាកាមនឹងទទួលបាននូវការយល់ ដឹងអំពីគោលបំណង និង លទ្ធផល ដែលរំពឹងទុក នៃ សិក្ខាសាលានេះ ។ | |
| **រយៈពេល:** | ០៥ នាទី | |
| **សម្ភារដែលត្រូវការ:** | ▪ ផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងសិក្ខាសាលា<br>▪ ឯកសារចែក ស្ដីអំពីគោលបំណងសិក្ខាសាលា | |
| **វត្ថុបំណង** | ***សកម្មភាពអ្នកសម្របសម្រួល*** | ***សកម្មភាពអ្នកចូលរួម*** |
| សិក្ខាកាមអាចកំណត់ពី គោលបំណង នៃ អង្គសិក្ខាសាលានេះ ។<br><br>សិក្ខាកាមអាចកំណត់បានពីផលរំពឹងទុករបស់ខ្លួនចំពោះសិក្ខាសាលា ។ | ▪ អ្នកសម្របសម្រួលបិទផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងសិក្ខាសាលារួចធ្វើការពន្យល់ ពី គោលបំណង, គោលដៅ និង លទ្ធផលដែលរំពឹងទុក នៃ អង្គសិក្ខាសាលានេះ ។<br><br>**គោលបំណងសិក្ខាសាលា** ផ្ដល់ការហ្វឹកហ្វឺនដល់ក្រុមគាំទ្រកម្មវិធី **IPM** នៅតាមសាលានីមួយៗ ឱ្យគេមានសមត្ថភាពក្នុងការដឹកនាំ គ្រប់គ្រង និង ផ្សព្វផ្សាយកម្មវិធី **IPM** នៅតាមសាលា និង សហគមន៍ របស់ពួក គេដើម្បីឱ្យគេចូលរួម ។<br>**គោលបំណងជាក់លាក់**<br>- ធ្វើការជ្រើសរើសគ្រូ **IPM** ២នាក់សម្រាប់បញ្ជូន ឱ្យទៅទទួលការហ្វឹកហ្វឺននៅខេត្តនិងមកផ្ដល់ការហ្វឹកហ្វឺនដល់សិស្សនៅតាមសាលាជាបន្ត ។<br>- ធ្វើការជ្រើសរើសសិស្សដែលត្រូវចូលរៀន **IPM**<br>- កំណត់ទីតាំងស្រែ ដែលនឹងត្រូវយកមកធ្វើជាស្រែ បង្ហាញ និង ធ្វើការចរចាជាមួយម្ចាស់ស្រែ ។<br>- ធ្វើការផ្សព្វផ្សាយកម្មវិធី អាយភីអ៊ឹម ដល់អាណា ព្យាបាល សិស្ស និង សហគមន៍ទាំងមូល ។<br>- បង្កើតគណៈកម្មការគ្រប់គ្រងកម្មវិធី អាយភីអ៊ឹម ឬក្រុមគាំទ្រ អាយភីអ៊ឹម ប្រចាំសាលា ។<br>**ផលរំពឹងទុក**<br>បង្កើតផែនការរៀបចំសាលារៀនស្រែសិស្ស **IPM** តាមសាលា ។ | ▪ សិក្ខាកាម ស្ដាប់ការអត្ថាធិប្បាយរបស់អ្នកសម្របសម្រួលដោយប្រុងប្រយត្ន័ ។ |
| ធ្វើការវាស់ក៏រិតយល់ដឹងរបស់សិក្ខាកាម ។ | ▪ អ្នកសម្របសម្រួលលើកជាសំណួរដើម្បីសាកល្បងវាស់ស្ទង់ការយល់ដឹងរបស់សិក្ខាកាម ។ ឧទាហរណ៍<br>- តើគោលបំណងជាក់លាក់នៃសិក្ខាសាលានេះជាអ្វី?<br>- តើផលរំពឹងទុក នៃសិក្ខាសាលានេះជាអ្វី? រយៈពេល?<br>▪ អ្នកសម្របសម្រួលចែកឯកសារស្ដីពីគោលបំណងសិក្ខាសាលា ។ | ▪ សិក្ខាកាមឆ្លើយសំណួរដែលលើកឡើងដោយអ្នកសម្របសម្រួល ។ |

2

<table>
<tr><th colspan="3">វគ្គទី២: ការពណ៌នាពីកម្មវិធី អាយ ភី អ៊ឹម</th></tr>
<tr><td>ខ្លឹមសារនិងសេចក្តីសង្ខេបៈ</td><td colspan="2">២,១. អាយ ភី អ៊ឹមជាអ្វី ?<br>ប្រវត្ត និង និយមន័យ របស់ អាយ ភី អ៊ឹម</td></tr>
<tr><td>រយៈពេលៈ</td><td colspan="2">៣០ នាទី</td></tr>
<tr><td>សម្ភារដែលត្រូវការៈ</td><td colspan="2">អាយភីអ៊ឹម Poster<br>ឯកសារចែក ស្តីអំពី អាយ ភី អ៊ឹមជាអ្វី?</td></tr>
<tr><td>▪ សិក្ខាកាមអាចកំណត់ ពី អត្ថន័យនៃពាក្យ អាយភីអ៊ឹម</td><td>▪ អ្នកសម្របសម្រួល សសេរពាក្យ អាយភីអ៊ឹម លើក្តារខៀន និងចាប់ផ្តើមធ្វើការពិភាក្សា ដោយលើកជា សំណួរថា " តើ អាយភីអ៊ឹម ជាអ្វី? "<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រារាល់ចម្លើយទាំងអស់លើក្តារ ខៀន ហើយធ្វើការពន្យល់អត្ថន័យអាយភីអ៊ឹមដូចខាងក្រោមៈ<br><u>អាយភីអ៊ឹមគឺជាវិធីសាស្ត្រដាំដុះដំណាំកសិកម្មពិសេសមួយ</u><br>▪ អាយភីអ៊ឹមជាមធ្យោបាយកសិកម្មមួយដែលនាំកសិករឆ្ពោះទៅរកការយល់ដឹងពីរបៀបដាំដុះដំណាំឱ្យបានល្អ បង្កើនទិន្នផលដំណាំរបស់ពួកគេ ដោយប្រើប្រាស់នូវវិធីសាស្ត្រចម្រុះ (សូម មើល Poster ) ដើម្បីកាត់បន្ថយជាអប្បរិមានូវផលប៉ះពាល់ដែលបណ្តាលមកពីការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺលើកសិផល របស់ពួកគេ។<br>▪ អ្នកសម្របសម្រួលបិទអាយភីអ៊ឹម Poster ហើយពន្យល់ថាតាមរយៈអាយភីអ៊ឹមកសិករធ្វើការវិពិចារណាលើកត្តាផ្សេងៗដែលជះឥទ្ធិពលលើដំណាំរបស់គេ សម្រាប់កសិករ អាយភីអ៊ឹម មានន័យថា វិធានការចម្រុះថែទាំដំណាំ។<br><br></td><td>▪ សិក្ខាកាម ឆ្លើយសំណួរ តាម ការយល់ឃើញរបស់ខ្លួន។</td></tr>
</table>

**អាយភីអ៊ីមគឺជាវិធីសាស្ត្រនៃការរៀនសូត្រ**

ក្នុងការអនុវត្តសកម្មភាព**អាយភីអ៊ីម** អ្នកចូលរួមដាំដំណាំលើស្រែបង្ហាញ ហើយធ្វើការតាមដានការដុះលូតលាស់របស់វារហូតដល់ពេលប្រមូលផល ។ អ្នកចូលរួមត្រូវបានគេធ្វើការបែងចែកជាក្រុមតូចៗដើម្បីឱ្យទទួលខុសត្រូវលើកូនស្រែ រឺ ថ្នាលបន្លែ ក្នុងដំណើរការមួយដែលហៅថា អែសា “***ការវិភាគប្រពន្ធ័អេក្សូត្របរិស្ថាន”*** អ្នកចូលរួមអាចមានលទ្ធភាពធ្វើការវិភាគ ស្ថានភាពនៃ កូនស្រែ រឺ ថ្នាលបន្លែ ជាពិសេសអំពី វត្តមាន, ចំនួន, ប្រភេទផ្សេងៗ, នៃសត្វល្អិត និង ធ្វើការសម្រេចចិត្ត លើការចាត់ចែងដើម្បីបន្ថយឥទ្ធិពលរបស់វា ។ ការពិសោធក៏ត្រូវបានគេធ្វើផងដែរដើម្បីរៀនសូត្របន្ថែមទៀតអំពីបរិស្ថាននៃចំការរបស់ពួលគេ, ដំណាក់កាលនៃការ វិវឌ្ឍន៏នៃដំណាំ និង ផលប៉ះពាល់ពីការបំផ្លាញពីសំណាក់សត្វល្អិត, សត្រូវផ្សេងទៀត, ស្មៅ និង ជម្ងឺលើដំណាំរបស់ពួកគេ ។ នៅពេលប្រមូលផល ការចំណាយក្នុងផលិតកម្ម និង ទិន្នផលត្រូវបានគេគណនា ដើម្បីឱ្យអ្នកចូលរួមធ្វើការប្រៀបធៀបលទ្ធផលដែលចេញពី ការចាត់ចែងការដាំដុះ តាមរបៀបផ្សេងៗដែលគេបានប្រើនៅលើ កូនស្រែ រឺ ថ្នាលបន្លែដែលគេទទួលខុសត្រូវ ។

**អាយភីអ៊ីម** ផ្តោតជាសំខាន់លើការសិក្សា អ្វីដែលកើតមានឡើងជាក់ស្តែងនៅនឹងវាលស្រែ គឺមិនមែនពីសៀវភៅនោះទេ ។ ដូច្នេះហើយបានជាគេច្រើនពិពណ៌នា ***អាយភីអ៊ីមយកស្រែជាសៀវភៅ*** សម្រាប់គ្រូ***អាយភីអ៊ីម*** គឺជាវិធីសាស្ត្រថ្មីនៃការបង្រៀន និង ការរៀនចំដំណើរការសិក្សារបស់សិស្ស សម្រាប់ពួកគេ ***អាយភីអ៊ីម*** មានន័យថា ***ការកែលំអវិធីសាស្ត្រគរុកោសល្យ*** ។

**IPM = Integrated Pest Management**
វិធានការណ៍ចំរុះថែរទាំដំណាំ

**IPM = Improving Pedagogical Methods**
ការកែលំអវិធីសាស្ត្រគរុកោសល្យ

- អ្នកសម្របសម្រួល លើកជាសំណួរថាតាមរយៈ អាយភីអ៊ីម តើកុមារបានសិក្សានូវមុខវិជ្ជាអ្វីខ្លះ? អ្នកសម្របសម្រួល ប្រមូលរាល់ចម្លើយដែលបានលើកឡើងដោយសិក្ខាកាម ហើយបិទចម្លើយទាំងនោះនៅជុំវិញពាក្យ អាយភីអ៊ីម ដូចរូបខាងក្រោម ។




- អ្នកសម្របសម្រួលធ្វើការបូកសរុបថាសាលារៀនស្រែសិស្ស អាយភីអ៊ីមគឺជាវិធីដែលមានប្រសិទ្ធភាពបំផុត សម្រាប់ការសិក្សា និង ការអនុវត្តរបៀបថ្មីនៃការបង្រៀនដែលក្រសួងអប់រំយុវជន និង កីឡា ហៅថា ***សិស្សមជ្ឈមណ្ឌល*** ។
- អ្នកសម្របសម្រួលបិទក្រដាសធំដែលបានសរសេរពាក្យគន្លិះដែលប្រើញឹកញាប់ក្នុងកម្មវិធី អាយភីអ៊ីមហើយធ្វើការពន្យល់ ។

**ពាក្យគន្លឹះក្នុងកម្មវិធីអាយភីអ៊ីម**

**សាលារៀនស្រែអាយភីអ៊ីម**

គឺជាវគ្គសិក្សាមួយដែលមានរយៈពេល១៨សប្តាហ៍សម្រាប់ដំណាំស្រូវ និង ១៤ សប្តាហ៍សម្រាប់ដំណាំបន្លែ ។

**សាលារៀនស្រែសិស្សអាយភីអ៊ីម**

គឺជាសាលារៀនស្រែអាយភីអ៊ីមដែលផ្តល់ការហ្វឹកហ្វឺនដល់សិស្សដែលមានចំនួនពី ២៥-៣០នាក់

**សាលារៀនស្រែគ្រូអាយភីអ៊ីម**

គឺជាសាលារៀនស្រែអាយភីអ៊ីមដែលផ្តល់ការហ្វឹកហ្វឺនដល់គ្រូដែលមានចំនួនពី ២៥-៣០នាក់

**សាលារៀនស្រែកសិករ អាយភីអ៊ីម**

គឺជាសាលារៀនស្រែអាយភីអ៊ីមដែលផ្តល់ការហ្វឹកហ្វឺនដល់កសិករដែលមានចំនួនពី ២៥-៣០នាក់

- អ្នកសម្របសម្រួល ចែកឯកសារស្តីអំពី អាយភីអ៊ីមជាអ្វី ? ដល់អ្នកចូលរួម ។

| ខ្លឹមសារនិងសេចក្តីសង្ខេបៈ | ២.២. គោលបំណង,ក្រុមគោលដៅនិងសារៈសំខាន់នៃការបញ្ចូលកម្មវិធី IPM ក្នុងកម្មវិធីសិក្សា<br>នៅក្នុងផ្នែកនេះសិក្ខាកាមនឹងទទួលបាននូវការយល់ដឹងអំពី គោលបំណងនៃកម្មវិធី អាយភីអ៊ឹម និង និយមន័យនៃពាក្យ អាយភីអ៊ឹម និង គោលការណ៍សំខាន់នៃកម្មវិធី អាយភីអ៊ឹម ។ | |
|---|---|---|
| រយៈពេលៈ | ៣០នាទី | |
| សម្ភារដែលត្រូវការៈ | ▪ ក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងនៃការបញ្ចូលកម្មវិធីIPMក្នុងកម្មវិធីសិក្សា<br>▪ ឯកសារចែក ស្តីអំពីគោលបំណងនៃការបញ្ចូលកម្មវិធី **អាយភីអ៊ឹម**ក្នុងកម្មវិធីសិក្សា | |
| ▪ សិក្ខាកាមអាចយល់ច្បាស់ពី គោលបំណងនៃកម្មវិធី **អាយភីអ៊ឹម** ។ | ក/ **គោលបំណង នៃការបញ្ចូលកម្មវិធី IPMក្នុងកម្មវិធីសិក្សា**<br>▪ អ្នកសម្របសម្រួលបិទក្រដាស់ធំដែលមានសរសេរពី គោលបំណង នៃកម្មវិធី **អាយភីអ៊ឹម**<br>**បំណងនៃកម្មវិធី អាយភីអ៊ឹម**<br>1. ដើម្បីផ្ទេរបច្ចេកទេសដាំដុះសមស្របមួយ(វិធីដែលមិនប៉ះពាល់បរិស្ថាន) ដល់សិស្ស និង សង្កត់ធ្ងន់លើដំណើរ នៃការអប់រំ ។<br>2. ធ្វើឱ្យការអប់រំកាន់តែមានភាពទាក់ទងទៅ នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ តាមរយៈការផ្តល់បំណិន និង បណ្តុះបណ្តាលកុមារ នូវការគិតគូរ វិភាគយ៉ាងល្អិតល្អន់ ។<br>3. ពង្រឹងទំនាក់ទំនងស្និទ្ធស្នាលរវាងសាលា និង សហគមន៍ ព្រមទាំងផ្តល់ឱកាសឱ្យសហគមន៍ ចូលរួមក្នុងការរៀនសូត្រ របស់កុមារ ។<br>អ្នកសម្របសម្រួលធ្វើការពន្យល់ថាៈ<br>▪ សាលារៀនស្រែសិស្សអាយភីអ៊ឹមមិនគ្រាន់តែជាកម្មវិធីមួយដែលជួយផ្ទេរចំណេះដឹងកសិកម្មដល់សិស្សានុសិស្សប៉ុណ្ណោះទេវាថែមទាំង ប្រើលំនាំអប់រំ តាមវិធីមួយហៅថា " **សិស្សមជ្ឈមណ្ឌល**" ដែលសិស្សត្រូវ គេណែនាំឱ្យសិក្សាដោយផ្ទាល់ តាមរយៈនៃការសង្កេត និង អនុវត្តន៍ ការងារក្នុងស្រែ និង ក្នុងថ្នាក់រៀន ។<br>▪ កុមារកម្ពុជាភាគច្រើនមកពីគ្រួសារកសិករ ជាពិសេសសាលាដែលនៅតំបន់ជនបទ ។ហេតុដូច្នេះ**អាយភីអ៊ឹម**ជាជំនាញមួយដែលសមស្របបំផុតសម្រាប់សិស្សនៅតាមសាលាជនបទ ។ ពួកគេអាចយកជំនាញនេះទៅជួយគ្រួសារ ហើយនឹងបង្កើននូវ បទពិសោធន៍ | ▪ សិក្ខាកាមស្តាប់ ការអត្ថាធិប្បាយរបស់អ្នកសម្របសម្រួលដោយប្រុងប្រយ័ត្ន ។ |

| | | |
|---|---|---|
| | កសិកម្ម ដ៏មានតម្លៃថ្មីៗទៀត ដែលប្រហែលជាអាច ជួយពួកគេក្នុងការប្រកបរបរចិញ្ចឹមជីវិតក្រោយពេលដែលពួកគេចាកចាញពីសាលា ។<br>▪ **អាយភីអ៊ីម** ផ្តល់ឱកាសល្អដើម្បីបង្កើន និង ពង្រឹងទំនាក់ទំនងរវាងសាលារៀន និង សហគមន៍ តាមរយៈសកម្មភាពមួយចំនួនដូចជា:<br>- សមាជិកសហគមន៍ជាប់ពាក់ព័ន្ធក្នុងដំណើរការរៀនសូត្ររបស់កុមារដោយចូលរួមក្នុងក្រុមបង្រៀន **អាយភីអ៊ីម** ។<br>- សាលារៀនស្រែសិស្ស **អាយភីអ៊ីម** ត្រូវបាន គ្រប់គ្រងដោយក្រុមគាំទ្រ អាយភីអ៊ីម តាមសាលានីមួយៗ ។<br>- សិស្សនឹងយកចំណេះដឹងនិងជំនាញដែលទទួលបានពីកម្មវិធីអាយភីអ៊ីម ទៅផ្ទះ និងចែករំលែកចំណេះដឹងនេះជាមួយឪពុកម្តាយ របស់ពួកគេ ។<br>- សាលារៀនស្រែសិស្ស **អាយភីអ៊ីម** លើកកំពស់ស្មារតី នៃការទទួលខុសត្រូវរបស់សាលាចំពោះ សហគមន៍លើលទ្ធផល នៃការងារអប់រំតាមរយៈការអញ្ជើញមាតា បិតាសិស្សឱ្យចូលរួមទស្សនកិច្ច និង ទិវាស្រែ ដែលពួកគាត់ អាចមើល ឃើញសកម្មភាពសិស្សធ្វើ និង ស្តាប់សិស្សធ្វើរបាយការណ៍ អំពីការសិក្សារបស់កុមារ ។<br><br>**សាលារៀនស្រែសិស្ស អាយភីអ៊ីម**<br>▪ ប្រើវាលស្រែធ្វើជាសៀវភៅ<br>▪ រៀនសូត្រដោយផ្អែកលើបទពិសោធនៃការអនុវត្តជាក់ស្តែង<br>▪ ធ្វើការសិក្សាពេញមួយវដ្តជីវិតនៃដំណាំ<br>▪ កម្មវិធីសិក្សាអាស្រ័យទៅនឹងស្ថានភាព បរិស្ថាន និង ប្រែប្រួលទៅតាមសេចក្តីត្រូវការចាំបាច់ ។ | |

## វគ្គទី ៣ ៈ ការរៀបចំដំណើរការសាលារៀនស្រែសិស្សមួយកន្លែង

| | |
|---|---|
| មេរៀន និងការសង្ខេប | ៣,១ ការបង្កើត គណៈកម្មការគ្រប់គ្រងកម្មវិធី រឺ ក្រុមគាំទ្រ អាយភីអ៊ឹម ប្រចាំសាលា<br>ផ្នែកនេះនឹងពិភាក្សាគ្នាពីភាពចាំបាច់ឱ្យមានគណៈកម្មការ រឺ ក្រុមគាំទ្រ អាយភីអ៊ឹមនៅតាមសាលានីមួយៗ និង កំណត់សមាសភាព, តួនាទីរបស់ គណៈកម្មការ រឺ ក្រុមគាំទ្រ អាយភីអ៊ឹម ។ |
| រយៈពេល | ៣០ នាទី |
| សម្ភារប្រើប្រាស់ | ▪ ឯកសារចែកស្តីអំពីតួនាទី/សមាសភាពរបស់ គណៈកម្មការគ្រប់គ្រងកម្មវិធី រឺ ក្រុមគាំទ្រ អាយភីអ៊ឹម ប្រចាំសាលា ។ |

| វត្ថុបំណង | សកម្មភាពអ្នកសម្របសម្រួល | សកម្មភាពអ្នកចូលរួម |
|---|---|---|
| សិក្ខាកាមអាចកំណត់ពីភាពចាំបាច់ឱ្យមាន គណៈកម្មការ គ្រប់គ្រង រឺក្រុមគាំទ្រកម្មវិធី អាយ ភី អ៊ឹម ប្រចាំសាលា ។<br><br>▪ សិក្ខាកាមកំណត់ពី សមាសភាព និង តួនាទី គណៈកម្មការ គ្រប់គ្រង រឺ ក្រុមគាំទ្រអាយភីអ៊ឹមប្រចាំសាលា ។ | ▪ អ្នកសម្របសម្រួលធ្វើការពន្យល់ថាមានភារកិច្ចជាច្រើនដែលត្រូវបំពេញមុនពេលចាប់ផ្តើមដំណើរការអនុវត្តសាលារៀនស្រែសិស្ស ។ កិច្ចការទាំងនោះវាជាការលំបាក់ក្នុងការទុកឱ្យមនុស្សម្នាក់ ឬ ពីរនាក់ជាអ្នកបំពេញ ។ អ្នកសម្របសម្រួលណែនាំគំនិតក្នុងការបង្កើត គណៈកម្មការ សម្រាប់គ្រប់គ្រង រឺ ក្រុមគាំទ្រកម្មវិធីអាយភីអ៊ឹមប្រចាំសាលា ហើយលើកសំណួរតើគេយល់ព្រមជាមួយនឹងគំនិតនេះដែរទេ?<br>▪ ប្រសិនបើក្រុមទាំងមូលមានការគាំទ្រឱ្យមាន គណៈកម្មការ សម្រាប់គ្រប់គ្រង ឬ ក្រុមគាំទ្រកម្មវិធី អាយភីអ៊ឹមប្រចាំសាលានោះ<br>▪ អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមជាក្រុមតូច ពី ៤—៦ នាក់ដើម្បីឱ្យគេ ធ្វើការពិភាក្សាលើសំណួរជាបន្តដូចជាៈ<br>▪ តើអ្នកណាខ្លះគួរចូលរួមក្នុងសមាសភាព គណៈកម្មការ គ្រប់គ្រង ឬក្រុមគាំទ្រ អាយភីអ៊ឹមប្រចាំសាលានេះ?<br>▪ តើគណៈកម្មការគ្រប់គ្រង ឬ ក្រុមគាំទ្រ អាយភីអ៊ឹមប្រចាំសាលា គួរមានតួនាទីអ្វីខ្លះក្នុងដំណើរការអនុវត្តកម្មវិធី អាយភីអ៊ឹម?<br>*ចម្លើយរំពឹងទុក*<br><br>**<u>សមាសភាព នៃ ក្រុមគាំទ្រ អាយភីអ៊ឹម</u>**<br>- នាយកសាលា<br>- អ្នកសម្របសម្រួល អាយភីអ៊ឹមប្រចាំសាលា<br>- តំណាងពីគណៈកម្មការទ្រទ្រង់សាលារៀន ឬ ឪពុកម្តាយសិស្ស | ▪ សិក្ខាកាមធ្វើការពិភាក្សាអំពីគំនិតក្នុងការបង្កើត គណៈកម្មការ សម្រាប់គ្រប់គ្រង រឺ ក្រុមគាំទ្រ កម្មវិធីអាយភីអ៊ឹមប្រចាំសាលា និង ផលប្រយោជន៍ ។<br><br>▪ សិក្ខាកាមអានសំណួរៗ ដល់ក្រុមទាំងអស់ស្តាប់ រួចធ្វើការពិភាក្សាតើអ្នកណាសមស្របសម្រាប់តួ នាទីនេះ ។ |

| | | |
|---|---|---|
| | **<u>តួនាទីគណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយ ភី អ៊ីម</u>**<br>- កំណត់ទីតាំងស្រែ ដែលនឹងត្រូវយកមកធ្វើជាស្រែបង្ហាញ និង ធ្វើការចរចាជាមួយម្ចាស់ស្រែ ។<br>- ធ្វើការជ្រើសរើសមនុស្ស២នាក់ដែលមានការចាប់អារម្មណ៏ ចង់ក្លាយជាអ្នកបង្រៀនអាយភីអ៊ីម សម្រាប់បង្រៀន ដល់ សិស្សនៅតាមសាលាជាបន្ត ។<br>- ធ្វើការជ្រើសរើសសិស្សដែលត្រូវចូលរៀន អាយភីអ៊ីមដោយផ្អែកលើគោលការណ៏ស្ម័គ្រចិត្ត ។<br>- ធ្វើការផ្សព្វផ្សាយកម្មវិធី អាយភីអ៊ីម ដល់អាណាព្យាបាលសិស្ស និង សហគមន៏ទាំងមូល ។<br>- ធ្វើការតាមដានដំណើរការអនុវត្តសាលារៀនស្រែសិស្ស ។<br>- ជួយចាត់ចែងឱ្យមាន ទិវាស្រែ និង ទស្សនកិច្ច របស់អាណាព្យាបាលសិស្ស ។<br><br>▪ អ្នកសម្របសម្រួលស្នើឱ្យក្រុមនីមួយៗបង្ហាញលទ្ធផលនៃការពិភាក្សារកយោបល់រួម លើសមាសភាព និងតួនាទីរបស៊ី គណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីមប្រចាំសាលា ។<br>▪ អ្នកសម្របសម្រួលបញ្ចប់ការពិភាក្សា ជាមួយនឹងការចែកឯកសារស្តីពី សមាសភាព និងតួនាទីរបស់ គណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីមប្រចាំសាលា ។ | សិក្ខាកាមធ្វើការកត់ត្រារួចចាត់ឱ្យតំណាងក្រុមឡើងបង្ហាញលទ្ធផលដែលចេញពីការពិភាក្សា ក្នុងក្រុមធំ ។ |

6

| មេរៀន និងការសង្ខេប | **៣.២ ការត្រៀមរៀបចំសម្រាប់សាលារៀនស្រែ អាយភីអ៊ឹម** ការជ្រើសទីតាំងសម្រាប់ ធ្វើស្រែបង្ហាញមួយ ការកំណត់លក្ខណៈសម្បត្តិរបស់អ្នកបង្រៀន អាយភីអ៊ឹម ការជ្រើសរើសសិស្ស និងការប្រជុំផ្សព្វផ្សាយកម្មវិធី អាយភីអ៊ឹមដល់សហគមន៍ ជាពិសេសអាណាព្យាបាលសិស្ស ។ | |
|---|---|---|
| **រយៈពេល** | ៦០ នាទី | |
| **សម្ភារប្រើប្រាស់** | ឯកសារចែក ស្ដីអំពីដំណើរការរៀបចំសាលារៀនស្រែសិស្ស **អាយភីអ៊ឹម** មួយកន្លែង | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| ▪ សិក្ខាកាមយល់ច្បាស់ពីជំហាននីមួយៗ ។ | ▪ អ្នកសម្របសម្រួលធ្វើការពន្យល់ថាៈដើម្បីអនុវត្តសាលារៀនស្រែសិស្សឱ្យមានប្រសិទ្ធភាពគណៈកម្មការឬក្រុមគាំទ្រ **IPM** ប្រចាំសាលានីមួយៗត្រូវត្រៀមជាស្រេចនូវ ការរៀបចំមួយ ចំនួនទុកជាមុន ។<br>▪ អ្នកសម្របសម្រួលលើកជាសំណួរដល់អ្នកចូលរួមតើជំហានទាំងនោះមានអ្វីខ្លះ?<br>▪ ក្រោយពីសិក្ខាកាមកំណត់ ជំហានទាំង៤នោះហើយ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមចូលក្រុមតូចហើយពិភាក្សាគ្នាលើសំណួរមួយជំហានម្តងៗ ។ | ▪ សិក្ខាកាមគិតពីជំហានទាំងនោះ ហើយផ្តល់ចម្លើយ ។ ចម្លើយរំពឹងទុកគឺ ៤ ជំហាន ។ |
| ▪ សិក្ខាកាមអាចកំណត់ទីតាំងសម្រាប់ ធ្វើស្រែបង្ហាញមួយកន្លែងដោយសមស្រប ។ | **ក. ការកំណត់ទីតាំងស្រែបង្ហាញ និង កន្លែងសិស្សរៀន**<br>▪ អ្នកសម្របសម្រួលពន្យល់ថាដើម្បីអនុវត្តសាលារៀនស្រែសិស្ស **IPM** យើងត្រូវការដីមួយកន្លែងសម្រាប់សិស្សធ្វើការអនុវត្តជាក់ស្តែង<br>▪ អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមជាក្រុមតូច ពី ៤ –៦ នាក់ ចែកក្រដាសធំ និង ហ្វឺតដល់ក្រុមទាំងអស់ ។<br>▪ អ្នកសម្របសម្រួល សរសេរសំណួរលើក្តារខៀន ឱ្យសិក្ខាកាមពិភាក្សា ក្នុងក្រុមតូច " តើយើងគួរ រើសស្រែដែលមាន លក្ខណៈសម្បត្តិយ៉ាង ណាដើម្បីងាយស្រួលឱ្យសិស្សធ្វើការអនុវត្ត?"<br>✶ អ្នកសម្របសម្រួលជួយផ្តល់នូវ គំនិតមួយចំនួនដល់ទកុមពិភាក្សា ដូចជា :<br>- ចម្ងាយពីសាលា រៀនទៅស្រែ, ភាពងាយស្រួលក្នុងការខ្ចីស្រែពីម្ចាស់, ភាពងាយ ស្រួលក្នុងការបញ្ចេញបញ្ចូលទឹក, ប្រភពទឹក,។<br>▪ ក្រុមតូចត្រឡប់ចូលមកក្នុងក្រុមធំវិញហើយធ្វើការបង្ហាញលទ្ធផល ដែលចេញពីការពិភាក្សា ។<br>▪ អ្នកសម្របសម្រួលធ្វើការបូកសរុបចម្លើយដើម្បីទុកធ្វើជាសេចក្តីណែនាំក្នុងការជ្រើសរើសទីតាំងស្រែបង្ហាញនិងទីកន្លែងសម្រាប់ឱ្យសិស្សរៀន អាយភីអ៊ឹម ។ | ▪ រៀបចំក្រុមតូចៗដោយខ្លួន ឯងពី ៤-៦នាក់ ។<br>▪ ធ្វើការពិភាក្សាក្នុងក្រុមដោយយកចិត្តទុកដាក់លើលក្ខណៈសម្បត្តិដែលត្រូវការចាំបាច់សម្រាប់ស្រែបង្ហាញ ។<br>▪ ធ្វើការកត់ត្រាចម្លើយលើក្រដាសធំ និង ឡើងបង្ហាញលទ្ធផលដែលចេញពីការពិភាក្សា ។ |

| | | |
|---|---|---|
| ▪ សិក្ខាកាមអាចកំណត់គ្រូ ធនធាន អាយ ភី អ៊ីម សម្រាប់ដឹកនាំបង្រៀនសិស្សក្នុងសាលារៀនស្រែសិស្សតាមសាលារបស់ពួកគេ។ | **កំណត់សំគាល់**<br>⋆ ដីស្រែដែលត្រូវការចាំបាច់សម្រាប់សាលារៀនស្រែសិស្សអាយភីអ៊ីម មួយគឺ គួរមានទំហំ<br>- ១០០០ម$^2$ លើដំណាំស្រូវ<br>- ១០០ ម$^2$ លើបន្លែ<br>⋆ គណ:កម្មការ រឺ ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលានិមួយៗត្រូវធ្វើកិច្ចព្រមព្រៀងជាមួយម្ចាស់ស្រែជាមុន។<br>⋆ កន្លែងសម្រាប់សិស្សសិក្សា អាយភីអ៊ីម អាចរើសយកបន្ទប់រៀន រឺ ក្រោមម្លប់ឈើ វាជាការល្អ មិនគួរឱ្យនៅឆ្ងាយពីស្រែពេកទេ។<br><br>**ខ. ការកំណត់អ្នកបង្រៀន អាយភីអ៊ីម**<br>▪ អ្នកសម្របសម្រួល ពន្យល់ថាយើងត្រូវការមនុស្ស ២ នាក់ ដើម្បីធ្វើជាអ្នកដឹកនាំសិស្សអនុវត្តសាលារៀនស្រែសិស្សអាយភីអ៊ីម។ អ្នកទាំងពីរនាក់នោះត្រូវទៅទទួលការហ្វឹកហ្វឺន ជំនាញ អាយភីអ៊ីម នៅខេត្តជាមុនសិន។<br>▪ អ្នកសម្របសម្រួល លើកជាសំណួរតើយើងគួររើស អ្នកបង្រៀន អាយភីអ៊ីម ដែលមានលក្ខណ:សម្បត្តិយ៉ាងណាសម្រាប់ឱ្យ ដឹកនាំបង្រៀនសិស្ស?<br>▪ អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមជាក្រុមតូច ពី ៤ – ៦ នាក់ដើម្បីឱ្យគេ ធ្វើការពិភាក្សាគ្នា។<br>▪ ចែកក្រដាសធំ និង ហ្វឺតដល់ក្រុមនីមួយៗដើម្បីឱ្យគេ ធ្វើការកត់ត្រាលទ្ធផលដែលចេញពីការពិភាក្សា។<br>▪ អ្នកសម្របសម្រួលអាចជួយសិក្ខាកាមធ្វើការពិភាក្សាដោយ ផ្តល់នូវគំនិតដែលត្រូវពិចារណាមួយចំនួនដូចជា: ចំណាប់អារម្មណ៍ លើការងារស្រែចំការកន្លងមក, ចំណូលចិត្តរៀនសូត្រពីអ្វីដែលថ្មី, ស្រឡាញ់កុមារ, ភាពជាគំរូល្អ,...។<br>▪ អ្នកសម្របសម្រួលធ្វើការបូកសរុបចម្លើយដើម្បីទុកធ្វើជាសេចក្តីណែនាំក្នុងការជ្រើសរើស អ្នកបង្រៀន អាយភីអ៊ីមប្រចាំសាលា របស់ខ្លួន។ | ▪ រៀបចំក្រុមតូចៗដោយខ្លួន ឯងពី ៤-៦នាក់ជាថ្មីម្តងទៀត។<br>▪ ធ្វើការពិភាក្សាក្នុងក្រុម ដោយយកចិត្តទុកដាក់លើលក្ខណ:សម្បត្តិ ដែលត្រូវការចាំបាច់សម្រាប់អ្នកបង្រៀនអាយភីអ៊ីម ធ្វើការកត់ត្រាចម្លើយលើក្រដាសធំ និង ឡើងបង្ហាញលទ្ធផលដែលចេញពីការពិភាក្សា។ |

**6**

| | | |
|---|---|---|
| | <u>**សំគាល់**</u><br>ក្នុងចំណោមអ្នកបង្រៀនអាយភីអ៊ីមប្រចាំសាលាទាំង២នាក់ ម្នាក់គួររើសចេញពីគ្រូបង្រៀនដែលមានការចាប់អារម្មណ៍នឹងការងារកសិកម្ម ឬជាអ្នកធ្វើស្រែក្រៅម៉ោងការងារ ហើយម្នាក់ទៀតគួរតែជាកសិករដែលមានបទពិសោធន៍ច្រើន។ | |
| សិក្ខាកាមកំណត់សិស្សដែលត្រូវចូលរួមក្នុងកម្មវិធីសាលារៀនស្រែសិស្សអាយភីអ៊ីមបានត្រឹមត្រូវ ។ | **គ, ការជ្រើសរើសសិស្ស**<br>▪ អ្នកសម្របសម្រួល ពន្យល់ថានៅក្នុងការអនុវត្ត សាលារៀនស្រែសិស្ស អាយភីអ៊ីម មានការងារខ្លះតម្រូវ ឱ្យប្រើពលកម្ម ដូចនេះ យើងត្រូវការសិស្សដែលមានកាយសម្បទាមាំមួន គឺ សិស្សធំៗ។ ដូច្នេះសាលានីមួយៗគួររើសសិស្សដែល ចេញពីថ្នាក់ទី ៥ និង ទី ៦។<br>▪ ចំនួនសិស្សសម្រាប់ សាលារៀន ស្រែសិស្ស អាយភីអ៊ីមមួយ គួរមានប្រហែល ៣០ នាក់ ពួកគេអាចមកពីថ្នាក់តែមួយ ឬក៏មកពីថ្នាក់ចម្រុះគ្នា មកពីសាលាតែមួយ ឬ មកពីសាលាផ្សេងគ្នាក្នុងកម្រងតែមួយ យ៉ាងណាកុំឱ្យតែគេត្រូវធ្វើដំណើរឆ្ងាយពេក។<br>▪ ក្រុមនីមួយៗគួរមានការចូលរួមស្មើគ្នារវាងសិស្សប្រុសនិង ស្ត្រី | |
| ▪ សិក្ខាកាមមានលទ្ធភាពកំណត់ អ្នកពាក់ព័ន្ធក្នុងកម្ម វិធីអាយភីអ៊ីមបានត្រឹមត្រូវ។ | **ឃ, ជួបប្រជុំជាមួយអាណាព្យាបាល**<br>▪ អ្នកសម្របសម្រួល ពន្យល់ថានៅក្នុងការអនុវត្ត សាលារៀនស្រែសិស្ស អាយភីអ៊ីមមានអ្នកពាក់ព័ន្ធជាច្រើន តើពួកគេជាអ្នកណាខ្លះ?<br>▪ អ្នកសម្របសម្រួលសរសេរពាក្យ ***សាលារៀនស្រែសិស្ស អាយភីអ៊ីម*** លើក្តារខៀន ហើយស្នើឱ្យអ្នកចូលរួមគិតមើលតើអ្នកណា ខ្លះជាអ្នកពាក់ព័ន្ធ ឬ ទទួលផលប្រយោជន៍ ពីកម្មវិធីនេះ។<br>ចម្លើយត្រូវសរសេរលើក្រដាស់**A4** រួចបិទជុំវិញពាក្យ ***សាលារៀនស្រែសិស្ស អាយភីអ៊ីម*** ចម្លើយរំពឹងទុក<br><br> | ▪ សិក្ខាកាម ឆ្លើយសំណួរតាម ការយល់ឃើញរបស់គេរៀងៗខ្លួន។ |

▪ ដោយផ្អែកលើលទ្ធផលនៃការពិភាក្សានេះ អ្នកសម្របសម្រួលគូរតារាងដូចខាងក្រោមដោយយកចម្លើយស្តីពីអ្នកពាក់ពន្ធ័មកដាក់បញ្ចូល

| **អ្នកពាក់ពន្ធ័** | **ហេតុអ្វីបានជាពួកគេចូលពាក់ពន្ធ័ក្នុងកម្មវិធី IPM** |
|---|---|
| សិស្ស | |
| គ្រូ | |
| នាយក | |
| ឪពុកម្តាយ | |
| សហគមន៏ | |
| រដ្ឋអំណាច | |

▪ អ្នកសម្របសម្រួលបន្តលើកជាសំណួរតើហេតុអ្វីបានជាអ្នកពាក់ព័ន្ធទាំងនោះចាប់អារម្មណ៍លើកម្មវិធី អាយភីអ៊ីម?

▪ អ្នកសម្របសម្រួលត្រូវសសេរចម្លើយទាំងនោះលើ តារាងធំនៅផ្នែកខាងស្តាំ។ ហើយលើកជាសំណួរបន្ត

- តើអក្នពាក់ព័ន្ធទាំងនោះបានដឹង ពីកម្មវិធី អាយភីអ៊ីមហើយឬនៅ?

ចម្លើយរំពឹងទុក **នៅទេ**

▪ អ្នកសម្របសម្រួល ពន្យល់ថាវាជាការសំខាន់ណាស់ក្នុងការប្រជុំជាមួយគណៈកម្មការ/ក្រុមគាំទ្រជ្រើសរើសរួច និង អាណាព្យាបាលសិស្ស រឺ តំណាងសមាជិកគ្រួសារ និង អ្នកបង្រៀនអាយភីអ៊ីម (អ្នកពាក់ព័ន្ធទាំងអស់)ដើម្បី បញ្ជាក់ ពីការទទួលខុសត្រូវរបស់ពួកគេម្នាក់ៗ ក្នុង កម្មវិធី សាលារៀនស្រែសិស្ស អាយភីអ៊ីម និង ស្នើសុំឱ្យគេចូលរួមសហការយ៉ាងពេញលេញលើកម្មវិធីនេះ។

**<u>កំណត់សម្គាល់</u>**

វាជាការសំខាន់ណាស់ដែលឪពុកម្តាយកុមារទាំងនោះត្រូវយល់ឱ្យបានច្បាស់ថា សាលារៀនមិនបានប្រើប្រាស់កម្លាំងពលកម្មកុមារទាំងនោះក្នុង *សាលារៀន ស្រែសិស្ស អាយភីអ៊ីម* ទេ តែវាគឺជាការរៀនសូត្រតាមរបៀបអនុវត្តផ្ទាល់ ហើយបទពិសោធន៏ដែលទទួលបានពីវគ្គនេះនឹងមានផលប្រយោជន៏ដល់អនាគតកុមារ ក៏ដូចជាគ្រួសារផ្ទាល់។

| | | |
|---|---|---|
| **មេរៀន និងការសង្ខេប** | **៤- ការកំណត់ថវិកា:**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី ដំណើរការដកប្រាក់ និង ទូទាត់ប្រាក់ដែលបានដក ក៏ដូចជាការកំណត់ថវិកាសម្រាប់ប្រតិបត្តិការកម្មវិធី អាយភីអុឹម ។ | |
| **រយៈពេល** | **៣០ នាទី** | |
| **សម្ភារះប្រើប្រាស់** | ▪ ក្រដាសផ្ទាំងធំ ហ្វឺត , ឯកសារចែកអំពី ថវិកាអាយភីអុឹម | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សក្មភាពអ្នកចូលរួម** |
| ▪ សិក្ខាកាមដែលជាក្រុម គាំ ទ្រ អាយ ភី អុឹមប្រចាំ សាលា អាចកំណត់បានពី ថវិកាដែលត្រូវ ការចាំបាច់ សម្រាប់ប្រតិបត្តិការ កម្មវិធី អាយ ភី អុឹម ។ | ▪ អ្នកសម្របសម្រួលពន្យល់ថា សាលាដែលបានស្នើសុំកម្មវិធីអាយភីអុឹមនៅក្នុងផែនការកែលំអកម្រងសាលារៀន ដែលបានឯកភាពគ្នារួចមកហើយអាចស្នើសុំថវិកាមួយចំនួនដូចខាងក្រោម:<br>- ប្រាក់ឧបត្ថម្ភអ្នកបង្រៀន អាយភីអុឹមប្រចាំសាលា២ នាក់ មួយថ្ងៃ ២,៥$ ក្នុងម្នាក់សម្រាប់ ១៨ ថ្ងៃ (IPM លើស្រូវ) និង ១៤ ថ្ងៃ (IPM លើបន្លែ)<br>- ប្រាក់សម្រាប់ អាហារសម្រន់  មួយថ្ងៃ ៥ដុល្លា សម្រាប់ ១៨ថ្ងៃ (IPM លើស្រូវ) និង ១៤ ថ្ងៃ (IPM លើបន្លែ)<br>- ប្រាក់សម្រាប់រៀបចំទស្សនកិច្ច និង ទិវាស្រែ អតិបរិមា ៣០ $<br>- សម្ភារះសម្រាប់សិក្សា អាយភីអុឹម ១៥០$ ក្នុងមួយសាលា<br>**ថវិកាសរុប ៣៦០ ដុល្លា** (IPM លើស្រូវ)<br>**៣២០ ដុល្លា** (IPM លើបន្លែ)<br>តែទោះជាយ៉ាងណាក៏ដោយ ថវិកាទាំងអស់នេះនៅមិនទាន់គ្រប់គ្រាន់សម្រាប់ដំណើរការកម្មវិធី ទាំងមូលបានទេយើងស្នើឱ្យសហគមន៍ ប្រើប្រាស់ឱ្យអស់លទ្ធភាព នូវធនធានដែលមានស្រាប់ជាពិសេសសម្រាប់រៀបចំឱ្យបាននូវ ទស្សនកិច្ចរបស់ មាតាបិតាសិស្ស  និង ទិវាស្រែបង្ហាញ ។ សម្រាប់ដំណើរការដកថវិកា នាយកសាលាដែលមានកម្មវិធី អាយភីអុឹមត្រូវធ្វើសំណើសុំថវិកានោះមកប្រធានកម្រងដោយផ្ជាប់មកជាមួយនូវផែនការអនុវត្តកម្មវិធីIPM និង ថវិកាត្រូវការ សម្រាប់ខែនោះ ។ ថវិការដែលផ្តល់ជាប្រាក់អោយខ្ចីមុនក្រុមគាំទ្រី IPM ប្រចាំសាលាត្រូវធ្វើការទូទាត់ជាក្រោយជាមួយ និង វិក័យប័ត្រចំណាយពិតប្រាកដ ។<br>អ្នកសម្របសម្រួលទុកពេលគ្រប់គ្រាន់សម្រាប់អ្នកចូលរួមធ្វើការពិភាក្សាគ្នា និង លើកជាសំណួរ រួចហើយចែកឯកសារស្តីពីថវិកា ។ | ▪ សិក្ខាកាមពិភាក្សា រឺ លើកជាសំនួរ បើឯកភាពគ្នា ធ្វើការកត់ត្រាដើម្បីទុកជាមូលដ្ឋានសម្រាប់ស្នើសុំថវិកា ។ |

**9**

| មេរៀន និងការសង្ខេប | **៥- ការធ្វើផែនការសកម្មភាព :**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី របៀបធ្វើផែនការសកម្មភាព សម្រាប់ ការរៀបចំសាលារៀនស្រែសិស្សអាយភីអ៊ីម នៅតាមសាលា ។ | |
|---|---|---|
| **រយៈពេល** | ៤៥ នាទី | |
| **សម្ភារប្រើប្រាស់** | ▪ តារាងផែនការ | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| ▪ សិក្ខាកាមដែលជាក្រុម គាំទ្រ អាយភីអ៊ីម ប្រចាំ សាលា ធ្វើផែនកាអេនុវត្តជាក់ស្តែង ច្បាស់លាស់សំរាប់យកទៅអនុវត្ត ។ | ▪ អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមដែលមកពីសាលាជាមួយគ្នាអង្គុយមួយក្រុមដើម្បីងាយស្រួលក្នុងរៀបចំធ្វើផែនការសកម្មភាពងាយភីអ៊ីម ។<br>▪ ក្រោយពីរៀបចំក្រុមរួចហើយ អ្នកសម្របសម្រួល ពន្យល់ថាពេលត្រឡប់ទៅវិញអ្នកទាំងអស់គឺជាអ្នកជួយធ្វើឱ្យកម្មវិធីអាយភីអ៊ីមចាប់ផ្តើមដំណើរការ ដូចនេះយើងត្រូវមានផែនការអនុវត្តច្បាស់លាស់សម្រាប់ធ្វើ ជាគោលក្នុងការអនុវត្ត ។<br>▪ អ្នកសម្របសម្រួល ចែកតារាងផែនការសកម្មភាពដល់ សិក្ខាកាម ទាំងអស់ ។<br>▪ អ្នកសម្របសម្រួល ធ្វើការពន្យល់ ពីរបៀប បំពេញតារាងមួយចំណុចម្តងៗ ធ្វើឱ្យប្រាកដថាសិក្ខាកាមអាច បំពេញតារាងផែនការនោះដោយខ្លួនឯង ។<br>▪ អ្នកសម្របសម្រួលអាចជួយក្រុមណាដែលមានការលំបាកក្នុងការបំពេញតារាងនោះ ។<br>▪ អ្នកសម្របសម្រួលបិទសិក្ខាសាលាដោយថ្លែងអរគុណដល់សិក្ខាកាម ដែលបានចំណាយពេលវេលាក្នុងការចូលរួមសិក្ខាសាលានេះ ។ អ្នកសម្របសម្រួល បញ្ជាក់ថា ក្រុមគាំទ្រអាយភីអ៊ីម ប្រចាំសាលាមានការទទួលខុស ត្រូវក្នុងការធ្វើឱ្យសាលារៀនស្រែសិស្សអាយភីអ៊ីមចាប់ដំណើរ ការហើយសូមជូនពរឱ្យសាលានីមួយៗទទួលបានជោគជ័យក្នុង ការអនុវត្តកម្មវិធី អាភីអ៊ីមនេះហើយណែនាំមនុស្សដែលត្រូវទាក់ទង ក្នុងករណីមានបញ្ហា ។<br>**កំណត់សំគាល់**<br>▪ តារាងផែនការត្រូវធ្វើជាពីរច្បាប់ មួយច្បាប់រក្សាទុកនៅតាមសាលារៀន និង មួយច្បាប់ទៀតត្រូវផ្តល់ជូនបុគ្គលិកអេស្កាប់ ។ | ▪ ពិភាក្សាគ្នាបំពេញតារាងផែនការ ។ |

# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

## ឯកសារ សម្រាប់អ្នកចូលរួម
## វគ្គតម្រង់ទិសស្តីពីវិធានការចម្រុះគ្រប់គ្រងដំណាំ

**សម្រាប់**

**សមាជិកក្រុមចម្បង នាយក អ្នកសម្របសម្រួល អាយតីអ៊ីម និង តំណាងសហគមន៍**

**វិច្ឆិការ ២០០៦**

# គោលបំណងសិក្ខាសាលា

ផ្តល់ការហ្វឹកហ្វឺនដល់ក្រុមគាំទ្រកម្មវិធី អាយភីអ៊ឹម នៅតាមសាលា នីមួយៗឱ្យគេមាន សមត្ថភាព ក្នុងការ ចាប់ផ្តើម ធ្វើការផ្សព្វផ្សាយ, បង្កើត, ដឹកនាំ, និង គ្រប់គ្រង កម្មវិធី អាយភីអ៊ឹម នៅតាមសាលា និង សហគមន៍ របស់ពួកគេ ។

គោលបំណងជាក់លាក់ក្រោយពីបញ្ចប់សិក្ខាសាលានេះ គឺអ្នកចូលរួមទាំងអស់ពេលត្រឡប់ទៅវិញផ្តួចផ្តើមធ្វើការ ពិភាក្សាដើម្បី:

- បង្កើតគណៈកម្មការគ្រប់គ្រងកម្មវិធី អាយភីអ៊ឹម រឺ ជាក្រុមការងារ អាយភី អ៊ឹម ប្រចាំ សាលា ។
- ធ្វើការជ្រើសរើសគ្រូ អាយភីអ៊ឹម ២នាក់ដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់ បញ្ជូន ឱ្យទៅទទួលការហ្វឹកហ្វឺន នៅខេត្តនិង ត្រឡប់មក ផ្តល់ការហ្វឹកហ្វឺនដល់ សិស្សនៅតាម សាលាជាបន្ត ។
- ធ្វើការជ្រើសរើសសិស្សដែលត្រូវឱ្យចូលរៀន កម្មវិធីអាយភីអ៊ឹម
- កំណត់ទីតាំងស្រែ ដែលនឹងត្រូវយកមកធ្វើជាស្រែបង្ហាញ និង ធ្វើការចរចាជាមួយម្ចាស់ ស្រែ ។
- ធ្វើការផ្សព្វផ្សាយពីកម្មវិធី អាយភីអ៊ឹម ដល់អាណា ព្យាបាលសិស្ស និង សហគមន៍ ទាំងមូលឱ្យបានយល់ច្បាស់លាស់ ។



# ១, អាយភីអ៊ីម ជាអ្វី ?

**ក,អាយ ភី អ៊ីមជា វិធីសាស្រ្តកសិកម្ម**




អាយភីអ៊ីម មកពីភាសាអង្គេសថា **Integrated Pest Management (IPM)** ដែលប្រែថា **វិធានការចម្រុះថែទាំដំណាំ** កម្មវិធី អាយភីអ៊ីមត្រូវបានបង្កើតឡើងនៅប្រទេស ឥណ្ឌូនេស៊ី ក្នុងទសវត្សឆ្នាំ ៨0 នៅក្រោយពេលដែលគេដឹងថាការប្រើប្រាស់ ថ្នាំពុលកសិកម្មកាន់តែធ្វើឱ្យសត្វល្អិតចង្រៃមានការកើនឡើងជាលំដាប់លើដំណាំរបស់កសិករ ហើយជាង នេះទៅទៀត វាបានបំផ្លាញតុល្យភាពធម្មជាតិ និង សុខ ភាព មនុស្សខ្លួនឯងផ្ទាល់តែម្តង ។

អ្នកស្រាវជ្រាវបានចាប់ផ្តើមសហការជាមួយកសិករ ដើម្បីរិះរកមធ្យោបាយ ផ្សេងទៀត ដើម្បីដោះស្រាយបញ្ហា កំណើននៃសត្វល្អិតចង្រៃ ដើម្បីទទួលទិន្នផលខ្ពស់ និង រក្សា បាននូវ  តុល្យភាពធម្មជាតិ និង សុខភាពមនុស្សទូទៅទៀតផង នោះគឺជាកម្មវិធី អាយភីអ៊ីម ។

**និយមន័យ**  អាយភីអ៊ីមគឺជាការចម្រុះបញ្ចូលគ្នានូវរាល់វិធីសាស្រ្តដាំដុះ ថែទាំ និង ការពារដំណាំប្រកបដោយប្រសិទ្ធភាពដោយគិតពិចារណាដល់និរន្តរភាព កសិកម្ម សេដ្ឋកិច្ច សង្គម និង បរិស្ថាន

**ខ, អាយភីអ៊ីម ជាវិធីសាស្រ្តសិក្សា**

យើងអាចនិយាយម្យ៉ាងទៀតបានថា អាយភីអ៊ីម គឺជាវិធីសិក្សាដ៏ល្អមួយផងដែរព្រោះថា គ្រូជាអ្នកសម្របសម្រួលការងារ ចំណែកសិស្សជាអ្នករៀបចំដាំដុះ និង គ្រប់គ្រង ត្រួតពិនិត្យមើលកាលូតលាស់របស់ដំណាំតាំងពីបណ្តុះឬសាបរហូតដល់ ប្រមូលផល ។ ស្រែពិសោធត្រូវបែងចែកជាកូនស្រែតូចៗហើយក្រុមសិស្សត្រូវបែងចែងឱ្យទទួលខុសត្រូវលើ កូនស្រែទីមួយៗ ។  សិស្សត្រូវធ្វើអង្កេត និង ប្រមូលទិន្នន័យរៀងរាល់សប្តាហ៍ នៅតាមកូនស្រែដែលខ្លួនទទួលខុសត្រូវ រួចហើយត្រូវធ្វើរបាយការណ៍មួយដែល គេហៅថា    " របាយការណ៍ វិភាគប្រពន្ធ័អេក្សូរបរិស្ថាន" សិស្ស អាចធ្វើការវិភាគ លើអ្វីៗ ដែលកើតមានឡើងនៅក្នុងកូន ស្រែនោះជា ពិសេស វត្តមានរបស់ សត្វ ល្អិតហើយធ្វើការសំរេចចិត្តលើ ការចាត់វិធានការផ្សេងៗ ។

ឆ្លងតាមបទពិសោធន៍នៅក្នុងកម្មវិធី អាយ ភី អ៊ីម វាជាបធ្យោបាយល្អមួយសម្រាប់ឱ្យសិស្សសិក្សាពី វដ្តជីវិតនៃដំណាំ មានដំណាក់កាលលូតលាស់នៃដំណាំ និង ផលប៉ះពាល់ដែលបណ្តាលមកពីសត្វល្អិត,ជំងឺ និង ស្មៅផ្សេងៗនៅក្នុងដំណាក់ កាលនីមួយៗ ។

គ. សិក្សា អាយភីអ៊ីម គឺសិក្សាលើមុខវិទ្យាចម្រុះ




លើការសិក្សានូវអ្វីដែល កើត ឡើង ជាក់ស្តែងក្នុងស្រែ មិនមែនលើការសិក្សាតាម សៀវភៅ ឯកសារ រឺ មេរៀនឡើយ យើងអាចហៅថា" ស្រែជាសៀវភៅ "ក្នុង អាយភីអ៊ីមសិស្សអាចអនុវត្ត ជាក់ស្តែងលើមុខវិជ្ជា ជីវវិទ្យា ភាសា/អក្សរសាស្ត្រ គណិតវិទ្យា សិក្សាសង្គម គំនូរ និង សេដ្ឋកិច្ច ។ល។

**អាយភីអ៊ីម = IPM (Integrated Pest Management ) វិធានការចំរុះថែទាំដំណាំ**

**អាយភីអ៊ីម = IPM (Improvement Pedagogy Methodology )វិធីសាស្ត្រកែលំអគុណភាពអប់រំ**

## ៉សាលារៀនស្រែសិស្ស អាយ ភី អ៊ីម

- ស្រែ រឺ ចំការជាប្រភពនៃការសិក្សា មានន័យថាសិស្សអាចប្រើប្រាស់ស្រែធ្វើជាប្រភពនៃការសិក្សាស្រាវជ្រាវ និង ដោយផ្អែកលើបទពិសោធន៍ ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់សិក្សា ។
- ការសិក្សាមានរយៈពេលពេញមួយវដ្តជីវិតនៃដំណាំ ។
- សាលានីមួយៗគួរតែ ជ្រើសរើសថ្នាក់ទី ៥ មួយថ្នាក់ និង ថ្នាក់ទី ៦ មួយថ្នាក់[១] មកអនុវត្តកម្មវិធីនេះដោយជ្រើសរើសចំនួនសិស្សច្រើនបំផុតត្រឹម ៣០ នាក់ ក្នុងនោះគួរមានសិស្សជាស្ត្រី ៥០% ។
- ការជ្រើសរើសសិស្សសម្រាប់ចូលរួមក្នុងកម្មវិធី **អាយ ភី អ៊ីម** ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និង ដោយមានការឯកភាពពី អាណាព្យាបាលសិស្សផង ។

## សារៈសំខាន់ក្នុងការរៀបចំកម្មវិធី អាយភី អ៊ីម

សារៈសំខាន់ក្នុងការរៀបចំកម្មវិធី **អាយភី អ៊ីម**

1. សាលារៀនស្រែសិស្ស អាយភីអ៊ីម គ្រប់គ្រងដោយ គណៈកម្មការ/ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលាដែលមានតំណាងពី សាលារៀន និង សហគមន៍ ។
2. សមាជិកសហគមន៍ចូលរួមក្នុងការបង្រៀន ។
3. សិស្ស ពិភាក្សាកិច្ចការធ្វើនៅផ្ទះ និង អ្វីដែលគេបានរៀន ជាមួយមាតាបិតារបស់គេ ។
4. សិស្សបង្ហាញការសិក្សារបស់ខ្លួនទៅកាន់មាតាបិតា គឺនៅក្នុងទិវាស្រែ និង ទស្សនកិច្ចមាតាបិតា ។

---

១ ដោយឡែកសំរាប់សាលានៅតាមជនបទដែលសិស្សថ្នាក់ទី ៥ និង ទី៦មានចំនួនតិច យើងអាចបន្ថែមថ្នាក់បាន ។

## ២, គោលបំណងនៃការបញ្ចូលកម្មវិធី អាយភីអ៊ីមទៅក្នុងកម្មវិធីសិក្សារបស់សិស្ស

### ក, ហេតុអ្វីយើងត្រូវបញ្ចូល កម្មវិធី អាយភីអ៊ីម ទៅក្នុងកម្មវិធីសិក្សារបស់សិស្ស

កម្មវិធីសាលារៀនស្រែសិស្ស អាយភីអ៊ីម ជាកម្មវិធីមួយដែលមិនគ្រាន់តែជួយផ្ទេរចំណេះដឹងកសិកម្មដល់សិស្សានុសិស្ស ប៉ុណ្ណោះទេវាថែមទាំង ប្រើលំនាំអប់រំតាមវិធីមួយហៅថា " សិស្សមជ្ឈមណ្ឌល " ដែលសិស្សត្រូវគេណែនាំឱ្យសិក្សាដោយផ្ទាល់ តាមរយៈនៃការ សង្កេត និង អនុវត្តន៍ការងារក្នុងស្រែ និង ក្នុងថ្នាក់រៀន ។ តាមរយៈការសិក្សា អាយភីអ៊ីម សិស្ស អភិវឌ្ឍន៍ បំណិនជាច្រើន ដូចជា ភាសា, គណិតវិទ្យា, និង វិទ្យាសាស្ត្រអនុវត្តន៍ ក្រៅពី នោះសិស្សក៏ត្រូវលើកទឹកចិត្តឱ្យរៀនសូត្រ ពី សីលធម៌ ផងដែរ ដូចជារបៀបធ្វើការជាក្រុម, ការទទួលខុសត្រូវ, ការសម្រេចចិត្ត, និង ការសិក្សាដោយឯករាជ្យ ។

### ខ, សាលារៀនស្រែសិស្ស អាយភីអ៊ីម ជួយពង្រឹងទំនាក់ទំនងសាលារៀន និង សហគមន៍

គោលបំណងក្នុងការបញ្ចូល **អាយភីអ៊ីម** ក្នុងកម្មវិធីសិក្សារបស់សិស្សគឺចង់បង្កើនទំនាក់ទំនងរវាងសាលារៀនជនបទ និង សហគមន៍ តាមរយៈសកម្មភាពមួយចំនួនដូចជា:

- ✶ កសិករចូលរួមក្នុងក្រុមបង្រៀន **អាយភីអ៊ីម**
- ✶ មានគណកម្មការគ្រប់គ្រងកម្មវិធី រឺ ជាក្រុមគាំទ្រ អាយភីអ៊ីម ដែលមានតំណាងភាគច្រើនពីសហគមន៍ ជួយគ្រប់គ្រង សាលារៀនស្រែសិស្ស អាយភីអ៊ីម ដូចជា ជ្រើសរើសត្រូធនធាន អាយភីអ៊ីម, រកស្រែសម្រាប់សិស្សពិសោធ,ជួយរៀបចំ ទស្សនកិច្ចមាតាបិតាសិស្ស, ទិវាស្រែ ។ល។
- ✶ សាលារៀនស្រែសិស្សអាយភីអ៊ីមក៏បានលើកកំពស់ស្មារតីនៃការទទួលខុសត្រូវរបស់សាលាចំពោះសហគមន៍លើលទ្ធ-ផល នៃការងារអប់រំ តាមរយៈការអញ្ជើញមាតាបិតាសិស្សឱ្យចូលរួមពិធីទស្សនកិច្ច និង ទិវាស្រែ ដែលពួកគាត់អាចមើល ឃើញសកម្មភាពសិស្សធ្វើ និង ស្តាប់សិស្សធ្វើរបាយការណ៍អំពីការសិក្សា ។
- ✶ សិស្សធ្វើការពិភាក្សាមុខវិជ្ជាអាយភីអ៊ីមជាមួយគ្រួសាររបស់ពួកគេ ដែលអាចឱ្យគ្រួសាររបស់ពួកគេជួយជាគំនិត និង សម្ភារ សម្រាប់សិក្សា ។

**<u>គោលបំណងនៃការ បញ្ចូលរបស់កម្មវិធី អាយភីអ៊ីមទៅ ក្នុង កម្មវិធីសិក្សារបស់សិស្ស</u>**

4. ពង្រីកការចាប់អារម្មណ៍របស់សិស្សក្នុងការសិក្សាតាមរយៈ ការ សិក្សាពីបរិស្ថាន និង សហគមន៍ របស់គេ ។
5. ធ្វើឱ្យការអប់រំកាន់តែមានភាពទាក់ទងទៅនឹងជីវភាព រស់នៅ របស់ កុមារតាមរយៈការផ្តល់បំណិនជីវិត និង បង្កើត ឱ្យមាន នូវជំនាញក្នុងការគិតគូរ វិភាគ និង គំនិតឆ្នៃប្រឌិត ។
6. ពង្រឹងទំនាក់ទំនងស្និទ្ធស្នាលរវាងសាលា និង សហគមន៍ ព្រមទាំងផ្តល់ឱកាសឱ្យសហគមន៍ ចូលរួមក្នុងការរៀន សូត្រ របស់កុមារ ។

# តួនាទីគណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលា

**១,សមាសភាព គណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលា**

សមាសភាព គណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលាគួរតែជាមនុស្សមកពី

- នាយកសាលា
- តំណាងគណៈកម្មការទ្រទ្រង់សាលារៀន
- តំណាងមាតាបិតាសិស្ស
- ចាស់ទុំដែលមានការចាប់អារម្មណ៍ និង បទពិសោធន៏កសិកម្ម

**២, ការទទួលខុសត្រូវរបស់ គណៈកម្មការគ្រប់គ្រង រឺ ក្រុមគាំទ្រ អាយភីអ៊ីម ប្រចាំសាលា**

ធ្វើការសហការគ្នាជាមួយ គ្រូបង្រៀន អាយភីអ៊ីម ប្រចាំសាលាដើម្បី

- កំណត់ទីតាំងស្រែ ដែលនឹងត្រូវយកមកធ្វើជាស្រែ បង្ហាញ និង ធ្វើការចរចាជាមួយ ម្ចាស់ស្រែ ។
- ធ្វើការជ្រើសរើសមនុស្ស២នាក់ដែលមានការចាប់ អារម្មណ៏ ចង់ក្លាយជាអ្នកបង្រៀន អាយ ភី អ៊ីម សម្រាប់ បង្រៀន ដល់ សិស្សនៅតាមសាលាជា បន្ត ។
- ធ្វើការជ្រើសរើសសិស្សដែលត្រូវចូលរៀន អាយភី អ៊ីម ។
- ធ្វើការផ្សព្វផ្សាយកម្មវិធី អាយ ភី អ៊ីម ដល់អាណា ព្យាបាល សិស្ស និង សហគមន៏ ទាំងមូល ។
- ធ្វើការតាមដានដំណើរការអនុវត្តសាលារៀនស្រែ សិស្ស និង ជួយចាត់ចែងឱ្យមាន ទិវាស្រែ និង ទស្សនកិច្ច របស់អាណាព្យាបាលសិស្ស ។

# ការត្រៀមរៀបចំសម្រាប់សាលារៀនស្រែសិស្ស អាយភីអ៊ីម

**ក. ការកំណត់ទីតាំងស្រែបង្ហាញ និង កន្លែងសិស្សរៀន**

ដីស្រែ ដែលត្រូវការចាំបាច់សម្រាប់សាលារៀនស្រែសិស្ស អាយភីអ៊ីម មួយកន្លែងគឺ គួរមានទំហំ ១០០០ម$^2$ សម្រាប់ IPM លើដំណាំស្រូវ និង ១០០$^2$ សម្រាប់ IPM លើបន្លែ ។ គណៈកម្មការ ឬ ក្រុមគាំទ្រ អាយ ភី អ៊ីម ប្រចាំសាលានីមួយៗត្រូវធ្វើកិច្ចព្រមព្រៀងជាមួយម្ចាស់ស្រែដើម្បីខ្ចីស្រែមកធ្វើការពិសោធ វាជាការងាយស្រួលប្រសិនបើស្រែនោះជាកម្មសិទ្ធរបស់សាលារៀន , សមាជិកក្រុមគាំទ្រ អាយភីអ៊ីម រឺ អ្នកបង្រៀន អាយភីអ៊ីម ប្រចាំសាលានោះផ្ទាល់តែម្តង។

ចំពោះកន្លែងសម្រាប់សិស្សសិក្សា អាយភីអ៊ីម ចាំបាច់ត្រូវរកទុកជាមុនយើងអាចប្រើបន្ទប់រៀន រឺ ក្រោមម្លប់ឈើ វាជាការល្អកន្លែងសម្រាប់សិស្សសិក្សា មិនគួរឱ្យនៅឆ្ងាយពីស្រែពេកទេ។

**ខ. ការកំណត់អ្នកបង្រៀនអាយ ភី អ៊ីម**

សម្រាប់ សាលារៀនស្រែសិស្ស អាយភីអ៊ីម មួយកន្លែងយើងត្រូវការឱ្យមានគ្រូបង្រៀន អាយភីអ៊ីមពីរនាក់ គឺម្នាក់ជាគ្រូបង្រៀន ដែលមានការចាប់អារម្មណ៍លើការងារកសិកម្ម ឬ កំពុងធ្វើស្រែចំការបន្ថែមលើការងារប្រចាំថ្ងៃដែលជាគ្រូបង្រៀន ។ ចំណែកឯម្នាក់ទៀតគួរតែជាកសិករដែលមានបទពិសោធច្រើនលើការងារកសិកម្ម។

ទោះជាយ៉ាងណាក៏ដោយការរើសយកបេក្ខជនទាំងពីរចាំបាច់ត្រូវតែមានការឯកភាពគ្នាជាឯកឆន្ទក្នុងចំណោម គណៈកម្មការ ឬ ក្រុមគាំទ្រកម្មវិធី អាយភីអ៊ីម ប្រចាំសាលា។

**គ. ការជ្រើសរើសសិស្ស**

នៅក្នុង ការអនុវត្តសាលារៀនស្រែសិស្ស អាយភីអ៊ីម មានការងារអនុវត្តច្រើន ដែលពេលខ្លះតម្រូវ ឱ្យប្រើពលកម្ម ដូច នេះ យើងត្រូវការសិស្សដែលកាយសម្បទាមាំមួន គឺ សិស្សធំៗ។ ដូច្នេះសាលានីមួយៗគួរើសសិស្សដែល ចេញពីថ្នាក់ទី ៥ និង ទី ៦ ចំពោះសាលាដែលគ្មានថ្នាក់ទី៦យើង អាចពិចារណាយកសិស្សខ្លះពីថ្នាក់ទី ៤មកចូលរួម។

ចំនួនសិស្ស សម្រាប់សាលារៀនស្រែសិស្ស អាយភីអ៊ីម មួយកន្លែង គួរមានប្រហែលពី ២៥ - ៣០ នាក់ ពួកគេអាចមកពីថ្នាក់តែមួយ ឬ ក៏មកពីថ្នាក់ចម្រុះគ្នា មកពីសាលាតែមួយ ឬ មកពីសាលាផ្សេងគ្នាក្នុងកម្រងតែមួយ យ៉ាងណាកុំអោយតែគេត្រូវធ្វើដំណើរ ឆ្ងាយពេក។ ក្រុមនីមួយៗគួរមានការចូលរួមស្មើគ្នារវាងសិស្សប្រុសនិង ស្រី។

**ឃ. ជួបប្រជុំជាមួយអាណាព្យាបាល**

វាជាការសំខាន់ណាស់ក្នុងការប្រជុំ ជាមួយគណៈកម្មការ/ក្រុមគាំទ្រ អាយភីអ៊ីម ដែលបានជ្រើសរើសរួច និង អាណាព្យាបាលសិស្ស រឺ តំណាងសមាជិកគ្រួសារ និង អ្នកបង្រៀន អាយភីអ៊ីម ដើម្បី បញ្ជាក់ ពីការទទួលខុសត្រូវរបស់ពួកគេម្នាក់ៗ ដែលពាក់ព័ន្ធក្នុង កម្មវិធី សាលារៀនស្រែសិស្ស អាយភីអ៊ីម និងស្នើសុំឱ្យគេចូលរួមសហការយ៉ាងពេញលេញ លើកម្មវិធី នេះ ។ (សូមមើលតារាងអ្នកពាក់ព័ន្ធ)

# អ្នកដែលពាក់ព័ន្ធនឹងកម្មវិធី  អាយភីអ៊ឹម

| អ្នកពាក់ព័ន្ធ | មូលហេតុដែលបណ្ដាលឱ្យអ្នកពាក់ពន្ធ័ទាំងនោះចាប់អារម្មណ៏លើកម្មវិធី អាយ ភី អ៊ឹម |
|---|---|
| សិស្ស | ✚ ពួកគេមួយចំនួនចូលរួមក្នុងកម្មវិធីសាលារៀនស្រែសិស្ស អាយភីអ៊ឹម<br>✚ រៀនសូត្រនូវចំណេះដឹងថ្មីៗ<br>✚ ជួយគាំទ្រកម្មវិធី |
| គ្រូ | ✚ គ្រូម្នាក់នឹងត្រូវជ្រើសឱ្យធ្វើជាអ្នកបង្រៀន អាយភីអ៊ឹម<br>✚ ជួយគាំទ្រកម្មវិធី |
| នាយក | ✚ ផ្ដល់ទីកន្លែង<br>✚ គាំទ្រការសិក្សារបស់សិស្ស |
| អាណាព្យាបាលសិស្ស | ✚ ជុំរុញកូនឱ្យមករៀនទៀងទាត់<br>✚ ផ្ដល់បទពិសោធន៏កសិកម្មដល់កូន<br>✚ ចង់បានអនាគតកូនល្អ |
| សហគមន៏ | ✚ គ្រួសារល្អនាំឱ្យសហគមន៏មានសេចក្ដីសុខ និង រីកចំរើន<br>✚ ចង់ចូលរួមក្នុងដំណើរការសាលារៀន កសិករម្នាក់ពីសហគមន៏ជាអ្នកបង្រៀន<br>✚ ចង់ចំណេះដឹងដល់កុមារជំនាន់ក្រោយ |
| អាជ្ញាធរមូលដ្ឋាន | ✚ ចង់ឱ្យសាលាមានដំណើរការល្អ<br>✚ ចង់បានការអប់រំល្អក្នុងមូលដ្ឋាន |

# ផែនការបង្កើតកម្មវិធី អាយ ភី អុឺម ប្រចាំសាលា

ឈ្មោះសាលា,................................................ កម្រង ........................................................

ឈ្មោះគណៈកម្មការ រឺ ក្រុមគាំទ្រកម្មវិធី អាយ ភី អុឺម

ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,.................................... ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,........................................

ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,.................................... ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,........................................

ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,.................................... ឈ្មោះ,........................................ តួនាទី បច្ចុប្បន្ន,........................................

| លរ | ជំហានអនុវត្ត | | | | | | | | | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| | សប្តាហ៍ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | |
| 1 | ចូលរួមសិក្ខាសាលា អាយ ភី អុឺម | | | | | | | | | |
| 2 | ប្រជុំផ្សព្វផ្សាយពីការងារ អាយភីអុឺម | | | | | | | | | |
| 3 | បង្កើតគណៈកម្មការ រឺ ក្រុមគាំទ្រកម្មវិធី អាយ ភី អុឺម | | | | | | | | | |
| 4 | រើសគ្រូសម្រាប់បង្រៀន អាយ ភី អុឺម | | | | | | | | | |
| 5 | រកស្រែសម្រាប់ធ្វើស្រែបង្ហាញ | | | | | | | | | |
| 6 | កំណត់សិស្ស រៀន អាយ ភី អុឺម | | | | | | | | | |
| 7 | បើកវគ្គ អាយ ភី អុឺម | | | | | | | | | |

ធ្វើនៅថ្ងៃទី ........... ខែ,............. ឆ្នាំ ២០០៦

ជ/ គណៈកម្មការ រឺ ក្រុមគាំទ្រកម្មវិធី អាយ ភី អុឺម ប្រចាំសាលា